00887244

E163/5/1/13/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 02 / 2013
ម៉ោង (Time/Heure): 13 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

**អង្គជំនុំជម្រះសាលាដំបូង**

ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ជូនចំពោះ៖** គ្រប់ ភាគីនៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13)

១. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13) ដែលមោឃភាពកិច្ចបំបែកដំណើរការនីតិវិធីសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសម្រេច អ.ជ.ត.ក")។[1] អ.ជ.ត.ក បានយល់ឃើញថា បណ្តឹងសាទុក្ខអាចទទួលយកបាន ដោយផ្អែកលើមូលហេតុដែលថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងគឺជាការបញ្ចប់នូវកិច្ចដំណើរការនីតិវិធី។ កិច្ចដំណើរការនីតិ

---

[1] ឥទ្ធិពលរបស់សេចក្តីសម្រេច អ.ជ.ត.ក មានវិសាលភាពចំពោះដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (ឯកសារ E124 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១), សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/7 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២), អនុស្សរណៈអជសដ ស្តីពី សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163/5 ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២) ព្រមទាំង "អនុស្សរណៈដែលជាប់ពាក់ព័ន្ធទាំងអស់" (សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ១៧)។

វិធីពាក់ព័ន្ធនឹងការចោទប្រកាន់ដែលនៅសេសសល់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះត្រូវបានពិចារណាដោយ អ.ជ.ត.ក ថា អាចមានអនុភាពទប់ស្កាត់មិនឲ្យមាន ដោយសារតែការលើកទៅជំនុំជម្រះនាពេលអនាគត ដោយសារតែវាទំនងជាថា សវនាការជាបន្តបន្ទាប់ក្នុងសំណុំរឿង ០០២/០១ នឹងមិនអាចប្រព្រឹត្តទៅបានឡើយ ដោយសារវ័យកាន់តែចាស់ និងសុខភាពកាន់តែធ្លាក់ចុះរបស់ជនជាប់ចោទ (សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ២៣-២៤)។ អ.ជ.ស.ដ ក៏ត្រូវបានទិតៀនផងដែរចំពោះការខកខានមិនបានគូសបញ្ជាក់អំពីផែនការច្បាស់លាស់មួយសម្រាប់ដំណើរការសវនាការទាំងនេះក្នុងពេលអនាគត (សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ២៤, ៤៦, ៤៧ និង ៥០)។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានរកឃើញបន្ថែមទៀតថា មានកំហុសក្នុងការបកស្រាយព្រំដែននៃឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដោយសារតែ អ.ជ.ស.ដ ខកខានមិនបានស្តាប់ភាគីនានាមុនពេលចេញដីកាបំបែកនីតិវិធី, ខកខានមិនបានផ្តល់ការពិចារណាគ្រប់គ្រាន់អំពីសេចក្តីត្រូវការនានា ដើម្បីធានាថា បទចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងសំណុំរឿង០០២/០១ មានលក្ខណៈជាតំណាងគ្រប់គ្រាន់ ចំពោះបទចោទប្រកាន់ទាំងអស់។ ជាចុងបញ្ចប់ អ.ជ.ត.ក ទំនងជាណែនាំឲ្យមានការបង្កើតអង្គជំនុំជម្រះសាលាដំបូងទីពីរសម្រាប់សវនាការនានានៃសំណុំរឿង ០០២ (សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ៥១)។

២. ផលវិបាកភ្លាមៗនៃសេចក្តីសម្រេច អ.ជ.ត.ក នេះគឺថា សំណុំរឿង ០០២ មិនត្រូវបានកំណត់វិសាលភាពទៀតទេ ហើយអង្គជំនុំជម្រះសាលាដំបូង បច្ចុប្បន្នមិនអាចដំណើរការចេញសាលក្រមលើសំណុំរឿង ០០២ បានទេ រហូតទាល់តែផ្នែកអង្គហេតុ និងបទចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ទាំងមូល ត្រូវបានជំនុំជម្រះ។ ទោះជាយ៉ាងនេះក្តី សេចក្តីសម្រេច អ.ជ.ត.ក បានធ្វើការចង្អុលបង្ហាញដូចខាងក្រោម៖

> ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបន្តពិចារណាលើអត្ថប្រយោជន៍យុត្តិធម៌ ដែលតម្រូវឲ្យបំបែកសំណុំរឿង ០០២ នោះ ជាដំបូង អង្គជំនុំជម្រះត្រូវអញ្ជើញភាគីនានាដាក់សារណារបស់ខ្លួនលើលក្ខខណ្ឌនៃដីកានេះ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបន្តពិចារណាលើអត្ថប្រយោជន៍យុត្តិធម៌ ដែលតម្រូវឱ្យបំបែកសំណុំរឿង ០០២ នោះ ជា[ដំ]បូង អង្គជំនុំជម្រះត្រូវអញ្ជើញភាគីនានាដាក់សារណារបស់[ខ្លួន]លើលក្ខខណ្ឌនៃដីកានេះ ហើយនៅពេលដែលអត្ថប្រយោជន៍របស់ភាគីទាំងអស់ ត្រូវបានធ្វើឲ្យមានតុល្យភាពចំពោះកត្តាពាក់ព័ន្ធផ្សេងៗហើយនោះ ការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ អាចធ្វើទៅបានប្រកបដោយភាពសមស្រប។ ជាការចាំបាច់ណាស់ថា អង្គជំនុំជម្រះសាលាដំបូងកំណត់ ដោយសំអាងលើការស្គាល់ជាខ្លឹមសារ លើសំណុំរឿង ០០២ លើបញ្ហាថាតើ អត្ថន័យនៃការបំបែកនេះ គឺស្ថិតក្រោមការរៀបចំរបស់តុលាការដែរឬយ៉ាងណា ក្នុងករណីនេះ មានភាពចាំបាច់សម្រាប់បង្កើតផែនការច្បាស់លាស់ជាក់ស្តែងសម្រាប់ការជំនុំជម្រះ លើបទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយមិនត្រឹមតែផ្តល់ព័ត៌មានជាផ្នែកតូចនោះទេ។ ប៉ុន្តែ ប្រសិនបើ នៅពេលប្រឈមមុខនឹងបញ្ហាសុខភាពរបស់ជនជាប់

ចោទចេះតែដុនដាបទៅ ការជំរុញទឹកចិត្ត គឺថា ត្រូវតែផ្តល់យុត្តិធម៌ឱ្យបានប្រសើរជាង តាមរយៈការបញ្ចប់ជាមួយនឹងការចេញសាលក្រម ទោះក្នុងករណីដាក់ពិរុទ្ធ ឬដោះលែង យ៉ាងហោចណាស់ លើការជំនុំជម្រះតូចមួយនៃផ្នែកខ្លះៗនៅក្នុងដីកាបញ្ជូនរឿង ទៅជំនុំជម្រះ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងគប្បីបញ្ជាក់ច្បាស់លាស់ និងផ្តល់ការពិចារណាសមស្រប ទៅលើការតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅជាការជំនុំជម្រះតូចជាងនេះ (សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ៥០) (សេចក្តីបញ្ជាក់បន្ថែម)។

៣. ដើម្បីអាចឱ្យអង្គជំនុំជម្រះសាលាដំបូងដោះស្រាយភាពមិនច្បាស់លាស់នាពេលនេះ ជុំវិញបញ្ហាវិសាលភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ និងដើម្បីកាត់បន្ថយការពន្យារពេលចំពោះការជំនុំជម្រះដែលកំពុងបន្តក្នុងសំណុំរឿង ០០២/០១ ឬផ្ទុយទៅវិញ ដើម្បីអនុលោមតាមសេចក្តីបង្គាប់របស់ អ.ជ.ត.ក អង្គជំនុំជម្រះសាលាដំបូងកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃ ព្រហស្បតិ៍ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃ សុក្រ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។[2] នៅក្នុងសវនាការនោះ ភាគីទាំងអស់ត្រូវបានស្នើឱ្យលើកឡើងយ៉ាងជាក់លាក់ដើម្បីដោះស្រាយបញ្ហាដូចខាងក្រោមនេះ៖

i. [*សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី*] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចពាក់ព័ន្ធផ្សេងទៀតរបស់ អ.ជ.ស.ដ ផ្ទុះបញ្ចាំងពីសេចក្តីបារម្ភដែលថា បទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០២ ទំនងជាមិនអាចត្រូវបានជំនុំជម្រះចប់សព្វគ្រប់ នៅក្នុងរយៈពេលដែលជនជាប់ចោទទំនងជាមានជីវិតរស់នៅ ឬក៏មុនពេលដែលជនជាប់ចោទទាំងនេះវិវត្តទៅជាមិនមានកាយសម្បទា និងប្រាជ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះឡើយ។ តើលោក/លោកស្រីមានការយល់ឃើញបែបណាចំពោះសេចក្តីបារម្ភនេះ?

ii. [*សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ*] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលពាក់ព័ន្ធនានារបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានជំរុញយ៉ាងច្បាស់ ដោយក្តីបារម្ភមួយ ក្នុងការរក្សាឱ្យបាននូវសមត្ថភាពរបស់អង្គជំនុំជម្រះដើម្បីចេញសាលក្រមឱ្យបានទាន់ពេលវេលានៅក្នុងសំណុំរឿង ០០២។ ជាបញ្ហាទូទៅ តើលោក/លោកស្រីចង់ឱ្យអង្គជំនុំជម្រះបន្តជំនុំជម្រះលើបទចោទ និងការចោទប្រកាន់ផ្នែកអង្គហេតុយ៉ាងច្រើនក្នុងលក្ខណៈទូលំទូលាយនៃសំណុំរឿង ០០២ ទាំងមូល ដោយលទ្ធផលចុងក្រោយប្រឈមនឹងការមិនទទួលបានសាលក្រម ឬក៏លោក/លោកស្រី

---

[2] សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ៥១៖ "...ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃដែលខ្លួនអា[ច]ធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទដែលសេសសល់ឱ្យបានឆាប់ដែលអាចធ្វើទៅបាន។"

ពិចារណាចង់ឲ្យដំណើរការកិច្ចនីតិវិធីដោយពាក់ព័ន្ធត្រឹមតែ បទចោទ និងការចោទប្រកាន់ផ្នែកអង្គហេតុមួយចំនួន ហើយដូច្នេះ វានឹងបង្កើនភវនីយភាពនៃការចេញសាលក្រមមួយបាន?

iii. [*សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ*] ខណៈពេលដែល អ.ជ.ត.ក ចេញសេចក្តីសម្រេចរបស់ខ្លួននេះ អង្គជំនុំជម្រះសាលាដំបូង កំពុងតែជិតនឹងឈានដល់ការបញ្ចប់សំណុំរឿង ០០២/០១។ មានការប៉ាន់ប្រមាណថា មានតម្រូវការចំនួនថ្ងៃសវនាការបន្តិចបន្តួចថែមទៀត ជាមួយនឹងវត្តមានជនជាប់ចោទទាំងបីនាក់ ដើម្បីបញ្ចប់សវនាការលើភស្តុតាងនៅក្នុងការជំនុំជម្រះលើកដំបូង។ ដោយសារតែការដាក់បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងដូចដែលបានប្រមើលដឹងជាមុនដោយអ្នកជំនាញវេជ្ជសាស្ត្រ ដែលបានពិនិត្យឡើងវិញលើសម្បទារបស់ជនជាប់ចោទទាំងអស់ក្នុងការចូលរួមសវនាការនោះ អង្គជំនុំជម្រះធ្លាប់បានជួបប្រទះនូវការពន្យារពេល និងផលវិបាកបន្ថែមទៀតក្នុងការទទួលបានវត្តមានរបស់ជនជាប់ចោទទាំងបីនាក់តាមពេលវេលាដែលបានកំណត់ ដោយសារតែការចុះដុនដាបផ្នែករាងកាយរបស់ពួកគាត់។ ដោយផ្អែកលើកាលៈទេសៈដែលមានការផ្លាស់ប្តូរនេះ និងផលវិបាកនានានៃការអនុវត្តវិធីសាស្ត្រណាមួយផ្សេង នៅដំណាក់កាលយឺតពេលទៅហើយនេះ តើលោក/លោកស្រីនៅតែជំទាស់ទៅនឹងការកំណត់របស់ អ.ជ.ស.ដ. ទៅលើវិសាលភាពនៃការជំនុំជម្រះដំណាក់កាលទីមួយរបស់ខ្លួន តាមរបៀបដែលត្រូវបានកំណត់ដោយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលពាក់ព័ន្ធនានាកន្លងមក ដែរឬទេ?

iv. [*សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ*] ប្រសិនបើលោក/លោកស្រី នៅតែរក្សាការស្នើសុំរបស់ខ្លួនក្នុងការពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ តើការស្នើសុំនេះកម្រិតត្រឹមការបន្ថែមលើការចោទប្រកាន់ផ្នែកអង្គហេតុដែលទាក់ទិននឹងមន្ទីរ ស-២១ និងស្រុក១២ ដែរឬទេ ឬក៏ លោក/លោកស្រីពិចារណាអំពីការណែនាំនៅក្នុងសេចក្តីសម្រេច អ.ជ.ត.ក ក្នុងការធានាអំពីភាពជាតំណាងបទចោទឲ្យបានគ្រប់គ្រាន់ ដើម្បីតម្រូវឲ្យមានបទចោទជាច្រើនក្នុងលក្ខណៈទូលំទូលាយដែរឬទេ? ដោយសារតែមន្ទីរស-២១ និងស្រុក១២ សំដៅលើវិសាលភាពភូមិសាស្ត្រមានកម្រិតមួយ និងបញ្ចូលតែផ្នែកតូចមួយនៃការរងគ្រោះទាំងមូលនៅក្នុងសំណុំរឿង០០២ ព្រមទាំងបង្ខំឲ្យអង្គជំនុំជម្រះស្តាប់សាជាថ្មីនូវការចោទប្រកាន់ទាក់ទិនតែនឹងទីតាំងឧក្រិដ្ឋកម្មតែមួយ ដែលត្រូវបានសម្រេចនៅចំពោះមុខអ.វ.ត.ករហូតមកទល់ពេលនេះ។ អង្គជំនុំជម្រះសាលាដំបូង បានកម្រិតសំណុំរឿង ០០២/០១ ជាសំខាន់ ទៅលើការផ្លាស់ទីលំនៅដោយបង្ខំ ដោយផ្អែកលើមូលដ្ឋានដែលថា បាតុភូតនេះប៉ះពាល់ជាសំខាន់ចំពោះជនរងគ្រោះស្ទើរតែទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជា អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សូមលោក/លោកស្រីផ្តល់យោបល់ ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ អ.ជ.ត.ក អំពីសេចក្តីតម្រូវដែលបានកំណត់អំពី ភាពជាលក្ខណៈតំណាង នេះ។

v. [*ភាគីទាំងអស់*] បច្ចុប្បន្ននេះ អ្នកជំនាញ លោកស្រី អេលីហ្សាប៉េត បេកខ័រ ត្រូវបានកំណត់កាលបរិច្ឆេទមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងអំឡុងសប្តាហ៍ ដែលចាប់ផ្តើមនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។ គ្រប់ភាគី និងអ្នកជំនាញផ្ទាល់ខ្លួនឯងបានត្រៀមខ្លួនចំពោះការផ្តល់សក្ខីកម្មនេះ ដែលស្ថិតនៅក្រោមការសន្មតថា វិសាលភាពនៃការផ្តល់សក្ខីកម្មនេះគួរតែត្រូវបានកម្រិតត្រឹមតែសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ វាមិនអាចអនុវត្តទៅបានទេ នៅក្នុងដំណាក់កាលនេះ ដែលតម្រូវឱ្យអ្នកជំនាញ និងគ្រប់ភាគីទាំងអស់ ធ្វើការរៀបចំចំពោះសក្ខីកម្មនេះ ដោយឈរលើមូលដ្ឋានមួយដែលមានលក្ខណៈផ្សេងគ្នាទាំងស្រុងនោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមស្នើឱ្យបន្តស្តាប់សក្ខីកម្មរបស់លោកស្រី អេលីហ្សាប៉េត បេកខ័រ និងគ្រប់បុគ្គលផ្សេងទៀត ដែលត្រូវបានកំណត់កាលបរិច្ឆេទឱ្យមកនៅចំពោះមុខអង្គជំនុំជម្រះនាពេលខាងមុខឆាប់ៗនេះ ដោយឈរលើមូលដ្ឋានវិសាលភាពនៃសវនាការ ដូចដែលបានកំណត់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចដែលពាក់ព័ន្ធនានា។ អង្គជំនុំជម្រះស្នើឱ្យភាគីទាំងអស់ផ្តល់យោបល់លើសំណើនេះ និងផលប៉ះពាល់ជាទូទៅកើតឡើងពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធទៅនឹងគ្រប់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅមុនការចេញសេចក្តីសម្រេចកែប្រែមួយរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើវិសាលភាពនៃសវនាការនៅក្នុងសំណុំរឿង ០០២/០១។

vi. [*ភាគីទាំងអស់*] ទាក់ទិននឹងការពង្រីកវិសាលភាពណាមួយនៃសំណុំរឿង០០២/០១ ដែលកំពុងនៅជាសំណើ សូមលោក/លោកស្រីបង្ហាញអំពីចំនួនឯកសារ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប៉ុន្មាន (ដោយរួមបញ្ចូលទាំងការកោះហៅបុគ្គលដែលបានស្តាប់សក្ខីកម្មរួចហើយផង) ដែលតម្រូវឱ្យដាក់ ឬកោះហៅ ដើម្បីជាការគាំទ្រ ឬបដិសេធចោលនូវសំណើសុំទាំងនេះ។ តើពេលណាជាកាលបរិច្ឆេទឆាប់រហ័សបំផុតដើម្បីអាចឱ្យលោក/លោកស្រីរៀបចំខ្លួន ដើម្បីលើកឡើង និងបង្ហាញអំពីឯកសារបន្ថែមទាំងនេះនៅក្នុងសវនាការ ប្រសិនជាចាំបាច់?

vii. [*ភាគីទាំងអស់*] អង្គជំនុំជម្រះបានបង្ហាញអំពីចេតនារបស់ខ្លួនដើម្បីបន្តសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០២ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន បន្ទាប់ពីបញ្ចប់សំណុំរឿង ០០២/០១។ ដោយសារតែការចោទប្រកាន់ទាំងអស់ផ្នែកអង្គហេតុ ទាក់ទិននឹងការជំនុំជម្រះតូចៗនីមួយៗ ដែលអាចកើតមាននៅក្នុងសំណុំរឿង០០២ បង្កើតបានជា ដីកាបញ្ជូនរឿងទៅជំនុំជម្រះរួមមួយ តើអង្គជំនុំជម្រះអាចបន្តសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០២ ក្រោយពីបញ្ចប់សវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ដែរឬទេ (ក្រោយពីការឈប់សម្រាករបស់តុលាការ ដែលអនុញ្ញាតឱ្យភាគីរៀបចំបានគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះតូចៗជាបន្តបន្ទាប់ និងស្របគ្នានឹងការធ្វើសេចក្តីព្រាងសាលក្រមក្នុងសំណុំរឿង០០២/០១)?

viii. [*ភាគីទាំងអស់*] អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីថា ការចោទប្រកាន់នៅសេសសល់ទាំងអស់នៅក្នុងសំណុំរឿង០០២ មិនមែនមិនបន្ត ដោយសារតែដីកាសម្រេចនោះទេ ប៉ុន្តែការចោទប្រកាន់នៅសេសសល់ទាំងនេះ គឺជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីនាពេលអនាគត ប្រសិនបើកាលៈទេសៈអនុញ្ញាត។ តើផលប្រយោជន៍អ្វីខ្លះដែលបន្ថែមដល់ភាគីនានាអំពីការកំណត់កាលបរិច្ឆេទច្បាស់លាស់នៃការជំនុំជម្រះជាបន្តបន្ទាប់ទាំងនេះ នៅពេលដែលការអនុវត្តដូចនេះពឹងផ្អែកទាំងស្រុងលើយថាភាពនានាដែលមិនអាចដឹងច្បាស់ (រួមមានទាំងការបន្តមានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទទាំងអស់ក្នុងការចូលរួមសវនាការ, ការផ្តល់ជំនួយរបស់អ្នកផ្តល់ជំនួយដើម្បីគាំទ្រដល់ការជំនុំជម្រះនាពេលអនាគត និងសម្មតិកម្មដែលថាសវនាការជាបន្តបន្ទាប់ទៀតអាចត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងមួយផ្សេងនោះ)?

ix. [*ក្រុមមេធាវីការពារក្តីទាំងអស់*] តើមោឃភាពលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ មានផលប៉ះពាល់អ្វីខ្លះលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស? ប្រសិនបើមានផលប៉ះពាល់ តើលោក/លោកស្រីយល់ឃើញថាមានវិធានការចាំបាច់អ្វីខ្លះ ដើម្បីជៀសវាង ឬដោះស្រាយចំពោះផលប៉ះពាល់ណាមួយដែលកើតឡើងចំពោះជនជាប់ចោទ ដោយសារតែមោឃភាពលើដីកាសម្រេចបំបែកសំណុំរឿងនេះ?

៤. សវនាការនៅថ្ងៃ ព្រហស្បតិ៍ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ នឹងស្តាប់សារណារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើបញ្ហាខាងលើនេះ និងអំពីបញ្ហាដទៃផ្សេងទៀតដែលចាត់ទុកថាពាក់ព័ន្ធ ហើយក្រុមមេធាវីការពារក្តីអាចនឹងឆ្លើយតបដោយសង្ខេប។ នៅថ្ងៃ សុក្រ ទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីទាំងអស់នឹងត្រូវបានអនុញ្ញាតឱ្យលើកឡើងនូវទឡ្ហីករណ៍របស់ខ្លួនហើយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ នឹងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីឆ្លើយតបដោយសង្ខេបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី។ ប្រសិនជាចាំបាច់ សវនាការស្តាប់សារណា និងការឆ្លើយតបនេះអាចនឹងបន្តនៅសប្តាហ៍បន្ទាប់ ក្នុងករណីសុខភាពរបស់ជនជាប់ចោទមិនអនុញ្ញាតឱ្យមានការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ លោកស្រី អេលីហ្សាប៊េត បេកខ័រ បាន នៅអំឡុងសប្តាហ៍ចាប់ផ្តើមពីថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ តាមការកំណត់ជាផែនការនាពេលនេះ។

៥. អង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្តីសម្រេចដោយមានសំអាងហេតុពេញលេញមួយ ទាក់ទិននឹងវិសាលភាពនៃសំណុំរឿង០០២/០១ ឱ្យបានឆាប់រហ័ស បន្ទាប់ពីសវនាការនេះ ដោយពិចារណាទៅលើសារណារបស់ភាគី និងគោលការណ៍នានា ដែលមាននៅក្នុងសេចក្តីសម្រេចរបស់ អ.ជ.ត.ក។